
TREASURE
Challenge
HUNT
ស្វែងរកកំណាប់


មើល ហ្ន!
ហាការី
និងម៉ាណាតើ!
តើអ្នកគិតថា
ពួកគេមកមាត់ទន្លេ
ជាមួយគ្នាឬ?




អូ! ហាការី
ឆ្មារបស់ខ្ញុំឈ្មោះម៉ូម៉ូ
ទៅចោលខ្ញុំហើយ!
ម៉ាណា
ឯងមាន
រឿងអីហ្នឹង?
ខ្ញុំជួយ!
តោះទៅរកវា!
មិនបាច់រកទេ!


Screeeech
BANG
គេបុក
វាស្លាប់
បាត់ហើយ ។




អូ!
ពិភពលោក
នេះអាក្រក់
ម្លេះ!
ហាការី
ឯងមាន
រឿងអី?
គី យូស៊ូកិ ត្រូវគេធ្វើ
បាបទៀតហើយ ។
ពួកគេចេះ
តែរករឿង
គាត់ ។
ឱ្យវ៉ែនតាខ្ញុំវិញ!
ឱ្យវិញភ្លាម!



បើគ្មានវ៉ែនតា យូស៊ូកិធ្វើអ្វីមិនកើតឡើយ សូម្បីតែដើរ។
គ្មានវ៉ែនតា ខ្ញុំមើលអត់ឃើញទេ!
ជនអាក្រក់នោះបានឆក់យកវ៉ែនតា។
ខ្ញុំត្រូវតែជួយ...
ឈប់ធ្វើបាបគាត់ភ្លាម!
ឯងគិតថាឯងជានរណា?
ឱ្យវ៉ែនតាវិញ!






ហាការី ឯងអត់អីទេ?
ម៉ាណា សុំទោស ខ្ញុំជួយអត់បាន។
ពួកគេគ្រវែងវ៉ែនតាទៅក្នុងស្មៅខ្ពស់ៗ ហើយរកយូរណាស់ទម្រាំឃើញ។
Fling
POP
ពេលយើងរកឃើញ វ៉ែនតាបាក់ដង ទៅហើយ!
ខ្ញុំស្អប់ពួកគេ!
ហេតុអ្វីមនុស្សល្អត្រូវគេធ្វើបាបរហូត?


ខ្ញុំចង់ដាល់ពួកគេណាស់!
ខ្ញុំចង់ក្លាយជាអ្នកខ្លាំងបំផុតដើម្បីវាយពួកគេទាំងអស់គ្នា!
ម៉ាណា ឯងមិនចង់បានអ្វីទេឬ? ចង់ខ្លាំង?
ពេលម៉ូម៉ូងាប់
យើងបានកប់វាត្រង់នោះក្បែរមាត់ទន្លេ ។
យប់នោះ ខ្ញុំចាប់ផ្តើមឆ្ងល់ ។
តើមានអ្វីកើតឡើងពេលឯងស្លាប់? ខ្ញុំធ្លាប់យល់សប្តិ៍អាក្រក់ ។
ខ្ញុំដូចជាខ្លាចពីព្រោះខ្ញុំអត់ដឹង...




នោះហើយដែលខ្ញុំចង់បាន គឺចម្លើយថាតើខ្ញុំទៅណាពេលស្លាប់?
អិម...
ឯងចង់បានចម្លើយ ខ្ញុំក៏ចង់បានចម្លើយដែរ ។
ខ្ញុំមានគំនិតមួយ ។ តោះប្រកួតគ្នារកចម្លើយ!
ឯងចង់ថាឯងរកវិធីធ្វើយ៉ាងម៉េចឱ្យបានខ្លាំង ។
ហើយឯងរកមើលអ្វីកើតឡើង ក្រោយឯងស្លាប់ ។



ខ្ញុំមិនចាំបាច់
ខ្លាចទៀតទេ ។
ហើយខ្ញុំក៏មិនចាំបាច់
ខឹងខ្លាំងទៀតដែរ!
សប្តាហ៍នោះ...
ហាស ហា
ខ្ញុំនឹងកម្ទេច
ពួកគេ!
មួយសប្តាហ៍ទៀត
ត្រលប់មកវិញ ប្រាប់
គ្នាអ្វីដែល
យើងរកឃើញ ។
ព្រម
មិនដឹងថា
រកឃើញចម្លើយ
ឬអត់ទេ...
ឆ្មា
ឆ្មាតើ!





សួរស្តី ចៅស្រី
ឈ្មោះអ្វីដែរ?
ខ្ញុំឈ្មោះ
ម៉ាណា ។


ចៅមកនេះ ញឹកញាប់ទេ ម៉ាណា?
ទេ ខ្ញុំមិនចូលចិត្តកន្លែងកប់ខ្មោចទេ...
មែនហើយ វាដូចជាគួរឱ្យខ្លាច បើចៅមិនស្គាល់...
ប្រាកដណាស់ គឺស្គាល់ព្រះយេស៊ូវ ។
ស្គាល់អ្វី?
យាយចង់និយាយថា ព្រះយេស៊ូវដែលកើតនៅថ្ងៃណូអែលឬ?
មែនហើយ ចៅស្រីឆ្លាតណាស់!
ដឹងហើយ ចៅមិនចូលចិត្តកន្លែងកប់ខ្មោច ព្រោះរំលឹកចៅថា យើងត្រូវស្លាប់ មែនទេ?




មែនហើយ ខ្ញុំខ្លាចស្លាប់ ។
យាយយល់ ។
តើយាយអាចប្រាប់រឿងដល់ចៅពីអ្វីដែលព្រះយេស៊ូវបានធ្វើជាមួយសេចក្ដីស្លាប់បានទេ?
មានក្មេងស្រីម្នាក់អាយុដំណាលចៅ ។
នាងឈឺយ៉ាងធ្ងន់
ធ្វើឱ្យឪពុកនាងរត់ទៅសុំអ្នកដំណើរម្នាក់ឱ្យជួយ ព្រោះគាត់ឮថាអ្នកនោះអាចប្រោសជំងឺបាន ។
អ្នកដំណើរនោះគឺព្រះយេស៊ូវ ។


តែមុនពេលឪពុកនាំព្រះយេស៊ូវមកដល់ផ្ទះ
មនុស្សប្រាប់គាត់ថា យឺតពេលហើយ នាងស្លាប់បាត់ហើយ ។
គ្រាន់តែជឿប៉ុណ្ណោះ ។
កុំព្រួយ
ព្រះយេស៊ូវ មានបន្ទូលដូច្នេះប្រាប់ឪពុក ។




ពេលទៅដល់ផ្ទះ ព្រះយេស៊ូវបានទៅ ជាមួយឪពុកម្តាយនាង
និងសិស្សទ្រង់ពីរបីនាក់ ទៅក្នុងបន្ទប់នាង ។
នាងតូច ក្រោកឡើង ។
ភ្លាមនោះ នាងបានងើបឈរ ដើរពេញបន្ទប់!


ឥឡូវនេះ ប្រាប់យាយមើល ក្រោយពីបានជួបព្រះយេស៊ូវហើយ តើចៅគិតថា ក្មេងស្រីនោះខ្លាចស្លាប់ទេ?
នាងឈប់ខ្លាចហើយ។
រើយ ច្រើនសប្តាហ៍ហើយ ខ្ញុំគ្មានចម្លើយសោះ។
ខ្ញុំបានជួបមនុស្សម្នាក់នៅវិទ្យាល័យដែលពូកែប្រដាល់។




ខ្ញុំចង់ដូចគាត់...
ប៉ុន្តែ ពេលគាត់ប្រដៅមនុស្សអាក្រក់ដែលកំពុងធ្វើបាបស្រីៗ...
ប៉ូលិសបែរជាទម្លាក់កំហុសលើគាត់ ហើយចាប់គាត់ទៅវិញ!
ខ្ញុំមិនជឿទេ!
ខ្ញុំបានរកឃើញអ្នកខ្លាំងពិតប្រាកដ! ខ្លាំងរហូតដល់យកឈ្នះសេចក្តីស្លាប់។


អ្នកនោះឈ្មោះព្រះយេស៊ូវ ។ ឯងដឹងទេ គឺព្រះយេស៊ូវរបស់បុណ្យណូអែល ។
ខ្ញុំបានជួបលោកយាយម្នាក់ គាត់ដឹងទាំងអស់អំពីព្រះអង្គ និងបានប្រាប់ខ្ញុំ ។
ថាម៉េច?
ព្រះយេស៊ូវព្យាបាលមនុស្ស
ប្រោសមនុស្សស្លាប់ឱ្យរស់វិញ...
ព្រះអង្គមានអំណាចលើព្យុះ អារក្ស និងរឿងគួរឱ្យខ្លាចទាំងអស់ ។
ខ្ញុំចង់ដឹងថែមទៀត ។
ហេតុអ្វីឯងមិនមើលអ្វីដែលឯងអាចដឹងបានពីព្រះយេស៊ូវដែរទៅ?




ដូច្នេះ ឯងឈប់ខ្លាចហើយឬ?
ចម្លែកណាស់ ខ្ញុំឈប់ខ្លាចហើយបែរជារំភើបចិត្តវិញ!
ព្រះយេស៊ូវ អេហ៎?
ប្រហែលខ្ញុំរកមើលសិន...


ឯអ្នកណាដែលចង់បានជាលេខ១ អ្នកនោះត្រូវធ្វើជាបាវដល់អ្នកទាំងអស់វិញ។
យេ! ព្រះយេស៊ូវ!
មែនហើយ ដូចជាកូនតូចនេះ
នៅក្នុងនគរព្រះ អ្នកតូចបំផុតគឺជាអ្នកធំបំផុត។
ចូរបន្ទាបខ្លួនដូចជាកូនក្មេង
ធី
ហ៊ី
ព្រះយេស៊ូវព្យាបាលខ្ញុំឱ្យមើលឃើញហើយ!
ស្អីគេ?!
អេហ៎! ក្រែងឯងជាមនុស្សខ្វាក់នោះអី?
ព្រះបិតាខ្ញុំនៅស្ថានសួគ៌ធ្វើការ
ខ្ញុំធ្វើការដែលទ្រង់ចង់ឱ្យធ្វើ
យី
ឯងថាព្រះជាឪពុកឯងឬ?!!
ប្រកាសថាជាព្រះតើ។ យើងមិនអត់ឱនទេ!!
អាហ៎
បិតា!
អាវ...
អត់ទោសឱ្យពួកគេផង ពួកគេមិនដឹងថាពួកគេកំពុងធ្វើអ្វីទេ។
ហាស ហាស មើលខ្លួនឯងទៅ!
បើឯងជាព្រះសង្គ្រោះ សង្គ្រោះខ្លួនឯងទៅ!
ឯងបានឃើញព្រះអង្គហើយមែនទេ?
ព្រះអង្គធ្វើអំពើល្អទាំងអស់។
ព្រះអង្គជួយមនុស្ស ពួកគេបែរជាឆ្កាងព្រះអង្គ។
តែព្រះអង្គបានធ្វើកិច្ចការយ៉ាងអស្ចារ្យ


ស្លាប់បានបីថ្ងៃ ព្រះអង្គរស់វិញ ។
គេមិនអាចបញ្ឈប់ព្រះអង្គឡើយ ទោះបើសម្លាប់ព្រះអង្គក៏ដោយ!
និយាយពីអំណាច! ព្រះអង្គអាចសម្លាប់មនុស្សអាក្រក់ទាំងនោះបាន ។
តែពេលព្រះអង្គព្យួរនៅលើឈើឆ្កាង ដឹងថាព្រះអង្គបានធ្វើអ្វីទេ?
ម៉ាណា ខ្ញុំរកឃើញចម្លើយខ្ញុំហើយ ។ អំណាចពិតប្រាកដឈ្មោះព្រះយេស៊ូវ ។
ព្រះអង្គអត់ទោសពួកគេ ។
ឯងផ្លាស់ប្ដូរហើយ ហាក់រី...




ពេលខ្ញុំអានរឿងព្រះគម្ពីរក្នុងកូនសៀវភៅនេះចប់ ខ្ញុំមានអារម្មណ៍ចង់អធិស្ឋាន ។
MANGA MESSIAH
ក្រោយអធិស្ឋានរួចហើយ ខ្ញុំមានអារម្មណ៍ល្អណាស់!
ខ្ញុំមានអារម្មណ៍អស្ចារ្យណាស់!
ខ្ញុំនិយាយថា ព្រះយេស៊ូវអើយ ខ្ញុំខុសហើយ ខ្ញុំសុំទោស ។ ព្រះអង្គជាអ្វីៗដែលខ្ញុំចង់ក្លាយជា ។ សូមជួយខ្ញុំឱ្យបានដូចជាព្រះអង្គ ។
អស្ចារ្យណាស់! ឯងដឹងទេ ខ្ញុំបានអធិស្ឋានដែរ!
ខ្ញុំមិនត្រឹមតែបាត់ព្រួយទេ ថែមទាំងមានអារម្មណ៍ចង់រាំទៀតផង ។
អេហ៎! តោះទៅ មាត់ទន្លេ!
តោះ


អេហ៎!
និយាយទៅ ព្រះយេស៊ូវជាមួយគ្នាទេ?
ខ្ញុំនឹកឃើញហើយ ។
ដូចម្ដេចបានឯងចេះ?
ចាំសិន! មានអ្នកផ្សេងទៀត...
គឺជាអ្នក!
អ្នកបានស្ដាប់រឿងយើង ។




ប៉ុន្តែ អ្នកក៏មានរឿងដែរ ។
មិត្តដែលឱ្យអ្នកកូនសៀវភៅនេះក៏មានរឿងផងដែរ ។
យើងបានធ្វើកិច្ចការនេះហើយ ។
ឥឡូវនេះ ដល់វេនអ្នកម្ដង!
ចាំឈើឆ្កាង នៅក្នុងរឿងដែរឬទេ?
យើងបានរៀនថា ឈើឆ្កាងនោះជួយយើងម្នាក់ៗច្រើនណាស់ ។
យើងម្នាក់ៗព្រងើយកន្តើយដាក់ព្រះ
ហើយធ្វើតាមចិត្តរបស់យើង ។
និយាយម្យ៉ាងទៀតថា យើងបានធ្វើបាប ។


ដោយព្រោះបាប យើងទាំងអស់មានគ្រោះថ្នាក់ ។
ពេលស្លាប់ទៅ យើងទាំងអស់គ្នាសមតែទទួលទោស
ដូច្នេះ ព្រះបានត្រលប់ជាមនុស្ស ។
ព្រះយេស៊ូវគ្រប់លក្ខណ៍ ហើយមិនដែលធ្វើខុសទេ ។




តែព្រះអង្គបានទទួលទោសជំនួសយើង
ហើយស្លាប់នៅលើឈើឆ្កាង ។
ឥឡូវនេះ ប្រាប់យើងថា ...


ខ្ញុំជាពន្លឺលោកិយ អ្នកណាតាមខ្ញុំ នោះមិនដែលដើរក្នុងសេចក្ដីងងឹតឡើយ គឺនឹងមានពន្លឺនៃជីវិតវិញ ។
ខ្ញុំជាអ្នកគង្វាលល្អ ឯអ្នកគង្វាលល្អ ក៏ស៊ូតែប្តូរជីវិតជំនួសចៀម ។
ខ្ញុំជាសេចក្តីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ ។






ព្រះយេស៊ូវអើយ ពិមុនមក ខ្ញុំមិនបានស្គាល់ព្រះអង្គទេ
ឥឡូវនេះ ខ្ញុំបានរៀនថា ព្រះអង្គស្រឡាញ់ខ្ញុំ។
ខ្ញុំក៏បានឮថា ព្រះអង្គបានស្លាប់នៅលើឈើឆ្កាងដើម្បី
ទទួលយកទោសដែលខ្ញុំសមនឹងទទួល។ ឥឡូវនេះ
ព្រះអង្គបានអត់ទោសឱ្យខ្ញុំ និងធ្វើជាមិត្តខ្ញុំ។
អរគុណព្រះអង្គ! សូមអត់ទោសកំហុសដែលខ្ញុំបានធ្វើ។
សូមជួយខ្ញុំឱ្យស្គាល់ព្រះអង្គកាន់តែច្បាស់ និងសូម
បង្ហាញខ្ញុំផ្លូវត្រឹមត្រូវ អាម៉ែន!




តើបានអធិស្ឋានដែរឬទេ?
អស្ចារ្យណាស់!
ដូចមិត្តភាពផ្សេងដែរ មិត្តភាពរបស់យើងជាមួយព្រះយេស៊ូវត្រូវរីកចម្រើនឡើង។
ព្រះអង្គចង់ធ្វើជាមិត្តល្អបំផុតរបស់យើង។
ព្រះអង្គនឹងណែនាំយើង ហើយជួយយើងរាល់ថ្ងៃ។
តើអ្នកគិតថាធ្វើយ៉ាងដូចម្ដេចឱ្យស្គាល់ព្រះអង្គកាន់តែច្បាស់?
ឥឡូវនេះ យើងសូមជម្រាបលាហើយ!
យើងមានមិត្តដទៃទៀតដែលត្រូវប្រាប់គេ។




ប៉ុន្តែ ត្រូវទៅមុខទៀត!
អ្នកទើបតែបានចាប់ផ្ដើមដំណើរជីវិតដ៏អស្ចារ្យបំផុត!



អត្ថបទ: អិនឌី មិកកូ    គំនូរ : មូហ្គី អៃយ៉ាម៉ា

**GospelShare Series Kids**
www.newdaytoday.net/gospel/en

Copyright © 2016 NewDayToDay
Illustrations from Manga Messiah Copyright © 2015 NEXT Manga
Design & Printing: New Life Ministries    Printed in Japan

In partnership with